ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន

MINISTRY OF INFORMATION

លេខ ០៧០ ព.ម

រាជធានីភ្នំពេញ. ថ្ងៃទី.......ខែ.........ឆ្នាំ.............

# សេចក្តីថ្លែងការណ៍

នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៩ សមាគមកម្ពុជាការពារអ្នកកាសែត បានចេញសេចក្តីថ្លែងការណ៍មួយទាក់ទិនទៅនឹងអ្វីដែលសមាគមនេះបានហៅថា ‹ប្រការដែលរដ្ឋាភិបាលមានបំណងដាក់កំរិតទៅលើការផ្សព្វផ្សាយតាមប្រព័ន្ធ **Internet**› ។

ក្រសួងព័ត៌មានសូមធ្វើការច្រានចោលនូវសេចក្តីប្រកាសព័ត៌មាន ដែលគ្មានមូលដ្ឋានពិតប្រាកដរបស់សមាគមកម្ពុជាការពារអ្នកកាសែត ដោយហេតុថា:

១. ការគ្រប់គ្រងប្រព័ន្ធ Internet មិនមែនជាភារកិច្ចរបស់ក្រសួងព័ត៌មានទេ ។

២. តាំងពីពេលមុន រហូតមកដល់ពេលបច្ចុប្បន្ននេះ នឹងទៅខាងមុខទៀត ក្រសួងព័ត៌មាន មិនមានគោលការណ៍ណាមួយក្នុងការត្រួតពិនិត្យការផ្សាយតាមប្រព័ន្ធ Internet ទេ។

៣. បច្ចុប្បន្នក្រសួងព័ត៌មានកំពុងតែរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីសោតទស្សន៍ ដែលសំដៅទៅលើការងារផ្សព្វផ្សាយវិទ្យុ ទូរទស្សន៍ និងរោងពុម្ពតែប៉ុណ្ណោះ។

៤. ក្រសួងព័ត៌មាន មានការសោកស្តាយយ៉ាងខ្លាំងចំពោះសមាគមកម្ពុជាការពារអ្នកសែត ដែលជាសមាគមមួយ មានអាយុកាលវែងក្នុងចំណោមសមាគមទាំង ១៨ ដែលកំពុងធ្វើសកម្មភាពនៅកម្ពុជា ហើយមិនបានយកចិត្តទុកដាក់ស្វែងរកព័ត៌មានពិត និង បានចេញសេចក្តីថ្លែងការណ៍មួយដែលប្រាសចាកពីការពិតទាំងស្រុង។

ជាថ្មីម្តងទៀត ក្រសួងព័ត៌មាន សូមធ្វើការបដិសេធចោលទាំងស្រុងនៅសេចក្តីថ្លែងការណ៍របស់សមាគមកម្ពុជាការពារអ្នកកាសែត (**CAPJ**) ។

រាជធានីភ្នំពេញ. ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៩